# ៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៨៩ ប្រក.វវស.បុ**

**ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល**

**រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជ រដ្ឋាភិបាល ។
- យោងតាមលិខិតលេខ: ២៦៧ សជណគបអ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើរៀបចំគណៈកម្មការ បច្ចេកទេសកែទំរង់រដ្ឋបាល តាមក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មាធិការមួយឈ្មោះថា «គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈដើម្បីកែទំរង់រដ្ឋបាល» ដែលជាចំណុចកណ្តាលរបស់ទីស្តីការគណៈ រដ្ឋមន្ត្រីសំរាប់ ÷

- ទំនាក់ទំនងជាមួយ គណៈកម្មាធិការអន្តរក្រសួង
- ដើម្បីពិគ្រោះពិភាក្សា និង សំរបសំរួលការងារបច្ចេកទេស អំពីការងារកែទំរង់រដ្ឋបាល ។

**ប្រការ ២** : គណៈកម្មាធិការបច្ចេកទេស របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល មានសមាសភាពដូចតទៅ ÷

១-ឯកឧត្តម **នុត ណារ៉ាង** រដ្ឋមន្ត្រី ជាប្រធាន

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិស៊ីរីរ័ទ្ធចំណារ៉ា** រដ្ឋលេខាធិការ ជាអនុប្រធាន

៣-ឯកឧត្តម **ម៉ែន យ៉េត** អនុរដ្ឋលេខាធិការ ជាអនុប្រធាន

៤-លោក **ស៊ិក ម៉ិនហុក** នាយខុទ្ទកាល័យ ជាសមាជិក

៥-លោក **ឈុំ គួង** ប្រធាននាយកដ្ឋានរដ្ឋបាល ជាសមាជិក

៦-លោក **ប្រាក់ គ្រួយ** ប្រធាននាយកដ្ឋានផែនការគណនេយ្យ ជាសមាជិក

៧-លោក **អ៊ឹក សុជាតិ** អនុប្រធាននាយកដ្ឋានបុគ្គលិក ជាសមាជិក

**ប្រការ ៣** : គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល មានភារកិច្ចដូចតទៅ ÷

- សិក្សាស្រាវជ្រាវ វិភាគ និងលើកយោបល់លើការជ្រើសរើសយកការកែទំរង់នាយកដ្ឋានចំណុះ និងមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត ក្រុង ជូនគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល ។
- ណែនាំ និងដំណើរការកម្មវិធីកែទំរង់
- ជំរុញ និងសំរបសំរួលនិងរៀបចំគ្រប់គ្រងការកែទំរង់របស់នាយកដ្ឋាន និងមន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង ។
- តាមដាននិងវាយតម្លៃលើការអនុវត្តកម្មវិធីនៃការកែទំរង់របស់នាយកដ្ឋាន និង មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង ។
- ធ្វើអោយមានលក្ខណៈប្រសើរក្នុងការផ្សព្វផ្សាយទូលំទូលាយនូវពត៌មានដែលបានមកពី គណៈកម្មការបច្ចេកទេសអន្តរក្រសួងដើម្បីកែទំរង់រដ្ឋបាលដល់នាយកដ្ឋាន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្តក្រុង ។

**ប្រការ ៤** : សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំ និងធ្វើការងារ តាមការអញ្ជើញ និងណែនាំរបស់ ប្រធាន ។

**ប្រការ ៥** : គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីកែទំរង់រដ្ឋបាល ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការបច្ចេកទេស អន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបំពេញការងាររបស់ខ្លួន ។

**ប្រការ ៦** : គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយប្រចាំការនៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាជំនួយការ ដែលមានសមាសភាពដូចតទៅ ÷

| | | | |
|---|---|---|---|
| ១–លោក | **ឡុង ទុន្ណី** | អគ្គនាយករងរដ្ឋបាល | ប្រធាន |
| ២–លោក | **ឆិត អ៊ីម** | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធានអចិន្ត្រៃយ៍ |
| ៣–លោក | **ខឹម សុខុម** | តំណាងនាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ៤–លោក | **អន សារ៉ី** | តំណាងនាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ៥–លោក | **ស្រី សួន** | តំណាងនាយកដ្ឋាន បុគ្គលិក | ជាសមាជិក |

**ប្រការ ៧** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស គ្រប់អង្គភាពក្រោមឱវាទក្រសួង និង អស់លោកដែលមានរាយនាមចែងក្នុងប្រការ ២ ប្រការ៦ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**នុត ណារ៉ាង**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៨៦

## ប្រកាសលេខ : ៩០ ប្រក.វចស.ប្

## ស្តីពីការផ្ទេរបណ្ណាល័យជាតិ និងក្របខ័ណ្ឌមន្ត្រីរាជការ